ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងអប់រំ យុវជន និងកីឡា បានសង្កេតឃើញថា ក្នុងពេលថ្មីៗនេះ មានការបង្ហោះព័ត៌មាននៅក្នុងប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមFacebook ពាក់ព័ន្ធនឹងបញ្ហាចាប់សិស្សសាលាបឋមសិក្សា ពេលចេញពីសាលារៀនទៅផ្ទះ។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួង សូមជម្រាបជូនដល់មាតា បិតា អ្នកអាណាព្យាបាល សាធារណជនទាំងអស់ជ្រាបថា ក្រសួង និងអជ្ញាធរមានសមត្ថកិច្ច ជាពិសេសនាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការនគរបាលជាតិ នៃក្រសួងមហាផ្ទៃ បានតាមដានយ៉ាងយកចិត្តទុកដាក់ ព្រមទាំងបានត្រៀមលក្ខណៈក្នុងការធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលា ក្នុងករណីមានសេចក្តីរាយការណ៍ពីសកម្មភាពសង្ស័យផ្សេងៗ ដែលនឹងឈានទៅធ្វើសកម្មភាពចាប់សិស្សសាលាជាក់ស្តែង កើតមានឡើង។

ដើម្បីឱ្យការអន្តរាគមន៍របស់អជ្ញាធរមានសមត្ថកិច្ចបានទាន់ពេល ធានាដល់សុវត្ថិភាពរបស់សិស្សសាលា ផ្តល់ភាពកក់ក្តៅដល់មាតា បិតា អ្នកអាណាព្យាបាល និងដើម្បីបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើរាជរដ្ឋាភិបាល នាយកដ្ឋានកណ្តាលសន្តិសុខ បានផ្តល់លេខទូរស័ព្ទចំនួនពីរខ្សែដូចខាងក្រោម ដើម្បីឱ្យ សាធារណជនផ្តល់ព័ត៌មាន រាយការណ៍រាល់សកម្មភាពសង្ស័យ ជូនដល់អជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការបង្ការ ទប់ស្កាត់ និងធ្វើអន្តរាគមន៍ឱ្យបានទាន់ពេលវេលា។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានណែនាំដល់គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ឱ្យធ្វើការផ្សព្វផ្សាយដល់គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទាំងអស់ ឱ្យមានការប្រុងប្រយ័ត្ន និងត្រៀមសហការជាមួយអជ្ញាធរមានសមត្ថកិច្ច។

ខ្សែទីមួយ៖ **០៣១ ២០ ១២៣៤៥**

ខ្សែទីពីរ៖ **០៣១ ៦០ ១២៣៤៥**

អាស្រ័យហេតុនេះ សូមមាតា បិតា អ្នកអាណាព្យាបាល សាធារណជន មេត្តាជ្រាប។

**រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០១៧**